# ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់

## តើអ្វីជាការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់?

ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់( យូភីអ )គឺជាយន្តការរបស់អង្គការសហប្រជាជាតិ (អ.ស.ប ) ដើម្បីពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សក្នុងរដ្ឋនីមួយៗនៅលើពិភពលោក។ ក្នុងអំឡុងពេល យូភីអ រដ្ឋដែលត្រូវបានពិនិត្យត្រូវបង្ហាញពីអ្វីដែលខ្លួនបានធ្វើពាក់ព័ន្ធនឹងការគោរពសិទ្ធិមនុស្សខណៈពេលដែលរដ្ឋជាសមាជិកផ្តល់ជាអនុសាសន៍ដើម្បីលើកស្ទួយស្ថានភាពសិទ្ធិមនុស្ស។




## តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីបាន?

- ផ្ញើរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋដែលត្រូវត្រួតពិនិត្យ
- ស្នើសុំឲ្យរដ្ឋដែលជាសមាជិក អ.ស.ប និង/ឬ ស្ថានទូតនៅក្នុងប្រទេសរបស់ខ្លួន សួរសំណួរជាក់លាក់និងផ្តល់អនុសាសន៍មួយចំនួនទៅរដ្ឋដែលត្រូវត្រួតពិនិត្យក្នុងអំឡុងពេលកិច្ចសន្ទនាបែបអន្តរកម្ម
- ចូលរួមនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស អំឡុងពេលការអនុម័តរបាយការណ៍ចុងក្រោយរបស់ យូភីអ
- តាមដានការអនុវត្តអនុសាសន៍របស់រដ្ឋ
- លើកកម្ពស់ការយល់ដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ អំពីការប្តេជ្ញាចិត្តរបស់រដ្ឋក្នុងការអនុវត្តអនុសាសន៍។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

www.cchrcambodia & www.sithi.org, ០២៣ ៧២៦ ៩០១, info@cchrcambodia.org

cc BY NC SA